# ធម្មទេសនារបស់លោកអភិបាលអូលីវីយេ
# អភិបូជាអភិបូជាជំហានទីពីរនៅវ្រៃធំ
# ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១៨

*អធិដ្ឋានដើម្បីភ្ជាប់ជាមួយព្រះជាម្ចាស់*

អត្ថបទទី១៖ ទក ៣០,១៥-២០
ដំណឹងល្អ៖ លក ៩,២២-២៥

បងប្អូនជាទីស្រឡាញ់!

រដូវ៤០ថ្ងៃ ជាពេលវេលាមួយពិសេស ដោយព្រះសហគមន៍ណែនាំឲ្យយើងកែប្រែចិត្តគំនិត ដើម្បីភ្ជាប់ជាមួយព្រះយេស៊ូថែមទៀត កែប្រែចិត្តគំនិតដើម្បីបម្រើព្រះសហគមន៍ថែមទៀត កែប្រែចិត្តគំនិតដើម្បីទៅជាមនុស្សថ្មី។ អត្ថបទគម្ពីរ "**បើអ្នកណាចង់មកតាមក្រោយខ្ញុំ ត្រូវលះបង់ខ្លួនឯងក្រោយលីឈើឆ្កាងរបស់ខ្លួន ហើយមកតាមខ្ញុំចុះ**" នៅក្នុងអត្ថបទទីមួយ "**សូមអ្នករាល់គ្នាដើរតាមមាគ៌ារបស់ព្រះអង្គ កាន់តាមក្រឹតវិន័យ និងច្បាប់ព្រះអង្គ**"។ ប្អូនដែលធ្វើជំហានទីពីរថ្ងៃនេះ ដោយសុខចិត្តធ្វើជាគ្រីស្តបរិស័ទនៅបុណ្យចម្លង។ យើងដើរតាមព្រះយេស៊ូមានន័យយ៉ាងម៉េច? ក្នុងជីវិតរបស់យើងយើងត្រូវតែតស៊ូ យើងមិនអាចធ្វើតាមសង្គមបានទេ។ នៅក្នុងសារលិខិតរបស់សម្តេចប៉ាបហ្វ្រង់ស៊ីស្កូ បានអញ្ជើញយើងឲ្យយើងទៅជាមនុស្សថ្មីដោយដកចេញអំពើទុច្ចរិតពីខ្លួនរបស់យើង។ ក្នុងនោះមានឃ្លាថា "**អំពើទុច្ចរិត អំពើអាក្រក់រីកចម្រើនខ្លាំង បណ្តាលឲ្យសេចក្តីស្រឡាញ់របស់មនុស្សមួយចំនួនធំត្រូវថយចុះ**" នៅពេលនោះសម្តេចប៉ាប បានរំលឹកឫសយ៉ាងជ្រៅដែលណែនាំឲ្យយើងប្រព្រឹត្តអំពើអាក្រក់ គឺដោយសារយើងស្រឡាញ់ទ្រព្យសម្បត្តិច្រើនពេក។ យើងជាគ្រីស្តបរិស័ទ យើងត្រូវតែជាមនុស្សខុសគេ ដើម្បីបង្ហាញថាអ្វីដែលសំខាន់សម្រាប់ជីវិតជាសេចក្តីស្រឡាញ់ មិនមែនទ្រព្យសម្បត្តិដែលយើងមាន។ យើងរស់នៅក្នុងបរិយាកាស ដែលសង្គមយកលុយជាព្រះជាម្ចាស់ ណែនាំឲ្យមានភាពអយុត្តិធម៌យ៉ាងច្រើន ដូចជាគេអនុញ្ញាតឲ្យសាងសង់កាស៊ីណូប៉ុន្មានក៏បាន ប៉ុន្តែពេលយើងសុំសាងសង់សាលាបឋមសិក្សានៅទីនេះមិនបាន។ លែងមើលឃើញផលប្រយោជន៍ដល់អ្នកដទៃ យើងចង់បានលុយយើងធ្វើអ្វីក៏បាន ប៉ុន្តែយើងចង់ជួយឲ្យកូនក្មេងមានអនាគតយើងគ្មានសិទ្ធិ។ ជីវិតរបស់យើងមានសុភមង្គល នៅពេលយើងយកចិត្តទុកដាក់ផ្តល់សុភមង្គលនិងសេចក្តីសុខដល់អ្នកដទៃ។ នៅក្នុងសង្គមណាក៏ដោយ មនុស្សម្នាក់ៗគិតតែងពីសេចក្តីសុខផ្ទាល់ខ្លួន ដោយភ្លេចគិតដល់អ្នកដទៃ ប៉ុន្តែព្រះយេស៊ូគ្រីស្តណែនាំឲ្យយើងលះបង់ចោល

ផលប្រយោជន៍ផ្ទាល់ខ្លួន ដើម្បីចេះមើលដល់បងប្អូនឯទៀតៗ។ដូង៤០ថ្ងៃនេះ ខ្ញុំសូមអញ្ជើញបងប្អូនទាំងអស់ដែលជាគ្រីស្តបរិស័ទបើកភ្នែកយ៉ាងធំ តើយើងធ្វើយ៉ាងណាដើម្បីផ្តល់សក្ខីភាពនៃសេចក្តីស្រឡាញ់ដល់អ្នកក្រីក្រ ដល់អ្នកតូចតានៅជុំវិញយើង។

ឆ្នាំគ្រួសារ ជាឱកាសមួយដើម្បីគិត តើគ្រួសារខ្ញុំធ្វើយ៉ាងណាដើម្បីគិតដល់អ្នកដទៃ? កុំឲ្យគ្រួសារខ្ញុំគិតតែផលប្រយោជន៍និងសុភមង្គលគ្រួសារខ្ញុំ។ យើងជាឪពុកម្តាយ តាយាយ ធ្វើយ៉ាងណែនាំដើម្បីណែនាំកូនៗរបស់យើងចេះមើលឃើញដល់បងប្អូនឯទៀតៗ។ សព្វថ្ងៃនៅក្នុងប្រទេសកម្ពុជាយើង មានកូនក្មេងយ៉ាងច្រើនដែលគ្មានឪពុកម្តាយ តែនៅទីនេះយើងមានសំណាងដោយសារឪពុកម្តាយរបស់យើងនៅជាមួយយើង។ ដូច្នេះឪពុកម្តាយត្រូវតែអប់រំកូន កុំឲ្យគេមើលតែសង្គមដែលចេះតែអាត្មានិយមដែលគិតតែប្រយោជន៍ផ្ទាល់ខ្លួន ប៉ុន្តែឲ្យគេចូលនៅក្នុងរបៀបព្រះយេស៊ូចាប់អារម្មណ៍ដល់អ្នកដទៃដែលកំពុងមានទុក្ខលំបាក។ សម្តេចប៉ាបនិយាយថា "**កុំឲ្យសេចក្តីស្រឡាញ់នៅក្នុងដួងចិត្តយើងទៅជាសេចក្តីស្រឡាញ់ដូចទឹកកក**" យើងធ្វើយ៉ាងណាឲ្យសេចក្តីស្រឡាញ់របស់យើង ទៅជាសេចក្តីស្រឡាញ់កក់ក្តៅដែលចេះស្រឡាញ់បងប្អូនឯទៀតៗពិតៗ។ ដើម្បីឲ្យយើងមានសេចក្តីស្រឡាញ់យ៉ាងកក់ក្តៅដល់បងប្អូនឯទៀតៗ គឺ៖

**ទីមួយ** អធិដ្ឋានដើម្បីភ្ជាប់ជាមួយព្រះជាម្ចាស់ ដើម្បីឲ្យព្រះយេស៊ូបំភ្លឺជីវិតរបស់យើងពិតៗ។ នៅក្នុងរដូវ៤០ថ្ងៃនេះ សូមបងស្រីបងប្រុស លោកឪពុក ផ្ញើអត្ថបទគម្ពីរដល់គ្រួសារនីមួយៗរាល់អាទិត្យ ដើម្បីឲ្យគេអធិដ្ឋានតាមផ្ទះដោយនឹកឃើញគម្ពីរដំណឹងល្អថ្ងៃអាទិត្យ ឲ្យគេជួបជុំគ្នានៅក្នុងផ្ទះដើម្បីអធិដ្ឋាន និងស្តាប់គម្ពីរដំណឹងល្អសារជាថ្មី ហើយសួរថាតើគម្ពីរថ្ងៃនេះបំភ្លឺជីវិតរបស់ខ្ញុំនិងជីវិតគ្រួសារដូចម្តេច?

**ទីពីរ** ឲ្យយើងចែករំលែកទ្រព្យសម្បត្តិដែលយើងមាន ដើម្បីឲ្យអ្នកដទៃមានសេចក្តីសុខដែរ។ សម្តេចប៉ាបបានអញ្ជើញយើងឲ្យយើងចូលនៅក្នុងរបៀបថ្មី នៅក្នុងវប្បធម៌ថ្មីឲ្យយើងជួយអ្នកដទៃទៅជាធម្មជាតិរបស់យើង។ ដោយសារ បញ្ហារបស់យើងឆាប់ភ្លេចទុក្ខលំបាករបស់បងប្អូនឯទៀតៗ។ ដូច្នេះនៅក្នុងរដូវ៤០ថ្ងៃ ឲ្យយើងសម្រេចចិត្ត តើព្រះសហគមន៍របស់យើងជួយអ្វីខ្លះដល់បងប្អូនឯទៀតៗ?

**ទីបី** ឲ្យយើងចេះតមអាហារ កាត់បន្ថយម្ហូបអាហារដើម្បីមូលអារម្មណ៍ជាមួយព្រះជាម្ចាស់ និងជាប់ជាមួយបងប្អូនឯទៀតៗថែមទៀត។ ឪពុកម្តាយ លោកតាលោកយាយ ត្រូវដើរតាមដានយុវជនដែលសព្វថ្ងៃនៅក្នុងសង្គមរបស់យើងមានគ្រឿងញៀនច្រើនណាស់ យើងត្រូវតែធ្វើប្រយ័ត្ន។ តមអាហារគឺយើងធ្វើប្រយ័ត្នអំពីទំលាប់យើងដែលមិនសូវល្អ ដើម្បីធ្វើជាមនុស្សថ្មីភ្ជាប់ជាមួយព្រះជាម្ចាស់ថែមទៀត និងអ្នកដទៃថែមទៀត។

ដូច្នេះនៅក្នុងរដូវ៤០ថ្ងៃនេះ យើងទទួលរបៀបពិសេសដើម្បីទៅជាសាវ័ករបស់ព្រះយេស៊ូ មិត្តសម្លាញ់របស់ព្រះយេស៊ូសារជាថ្មី។ ខ្ញុំសូមអញ្ជើញបងប្រុសបងស្រីនៅក្នុងមណ្ឌលសកម្មទន្លេបាសាក់ ដើម្បីសហការយ៉ាងជិតស្និទ្ធជាមួយលោកបូជាចារ្យ ដើម្បីឲ្យព្រះសហាគមន៍របស់យើងទៅជាព្រះសហាគមន៍ដ៏សុខសាន្ត។

ខ្ញុំសូមជូនពរឲ្យបងប្អូនទាំងអស់ឲ្យមានសុខភាពល្អ និងមានជំនឿរឹងមាំលើព្រះយេស៊ូក្នុងឱកាសឆ្នាំថ្មីនេះ។ អាម៉ែន៕